- Reçu le 25-1-51
140
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្តីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ



ឆ្នាំទី ១   សីហា   លេខ ៨

ព.ស. ២៤៩៣ – គ.ស. ១៩៥០

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម-ក្រសេម

សំណាក់ការ លេខ ៣៥ គ., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង

ទំព័រ

វិចារណកថា . . . . . . . . . . . . . . . . . . . . . . . . . . . . ២៨១

ការបងមិត្ត . . . . . . . . . . . . . ស្រី-អ៊ូ . . . . . . . . . . . . . ២៨៣

បទពិចារណាពីសៃទក្រុងពលី . . . . . ឈឹម-ក្រសេម . . . . . . . . . . ២៩១

ដំណើងការកសាងវត្តមួយនៅក្រុងព្រៃនគរ. សមាគមមិត្តសាលាបាលី . . . . . ២៩៩

ប្រវត្តិព្រះមហាវិមលធម្ម ថោង . . . . . . . . . . . . . . . . . . . . ៣០០

មរណៈនៃសត្វសេះ . . . . . . . . . . សាំង-សុវៀ . . . . . . . . . . . ៣០៤

ការសង្កេតខ្លះៗពីរបៀបតែងសេចក្ដី . . . សុភមិត្រ . . . . . . . . . . . ៣០៦

បញ្ចតន្ត្រៈ (តមក) សេចក្ដីប្រែរបស់ភិក្ខុ ប៉ាង-ខាត់ . . . . . . . . . . . ៣១១

សេចក្ដីថ្លែងការណ៍គណៈកម្មាធិការ . . . . . . . . . . . . . . . . . . ៣២០

---

ដំឡៃជាវ

- ១ ឆ្នាំ . . . . . . . . . . . . . . . ៩៦,០០
- ១ ឆមាស . . . . . . . . . . . . . ៤៨,០០
- ១ ត្រីមាស . . . . . . . . . . . ២៤,០០
- ១ ក្បាល . . . . . . . . . . . . . ៨,០០

---

អ្នកអានទាំងឡាយ៖ សូមអញ្ជើញចុះឈ្មោះជាវ!

និងបបួលញាតិមិត្តជួយជាវ។

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ៗ

# វិចារណកថា

ភាសាខ្មែរ ជាភាសារស់ គឺភាសាដែលគេនៅប្រើជាធម្មតា, ភាសាដែលមានជីវិតរស់រវើក ពុំមែនជាភាសាដែលគប់នៅតែក្នុងក្បួនសាស្ត្រានោះទេ ។ ឯពាក្យនៃភាសានេះ បីដូចវត្ថុមានជីវិតទាំងពួង រមែងប្រែប្រួលចាស់គ្រាំគ្រាឬចំរើនឡើងតាមកាលសម័យ ដូចពាក្យថា "រូហាន" "ញិង" ឬ "ពុំឃែួន" ជាដើម គេទុកជាពាក្យបុរាណលែងប្រើទៅហើយ ដោយមានពាក្យ "ដូច" "ក្រៃពេក" "ពុំល្មៀង" ប្រើជំនួសឡើង, នេះសំរាប់ពាក្យដែលស្លាប់ ។ ឯសេចក្ដីត្រូវការរបស់មនុស្សរេះតែមានប្លែកៗឡើងជាលំដាប់ ចំណេះវិជ្ជាសោតក៏រឹងរឹតតែរីកទូលាយធំឡើងដែរ ទើបបង្កើតវត្ថុនឹងសញ្ញាណថ្មីៗដែលគប្បីតែរកពាក្យសន្មតហៅ, ដូចប្រទេសយើងដែលបានដើរមកដល់ផ្លូវបត់ថ្មីមួយនៃពង្សាវតារ ត្រូវការពាក្យជាច្រើន ដើម្បីប្រើប្រាស់ឲ្យទាន់កាលសម័យ ។ ក្រុមជំនុំវប្បធម៌ក៏បានបង្កើតឲ្យមានឡើងក្នុងវត្ថុបំណងនេះ ។

សូម្បីក្រុមជំនុំនេះបានផ្ដល់ប្រយោជន៍ដ៏សំខាន់ ចំពោះភាសាជាតិយ៉ាងណា គង់មានពួកពាក្យរអ៊ូរទាំច្រើនគួរសមដែរ, អ្នកមិនដើរទៅមុខនឹងអ្នកទៀតឡាក្រោយគេ តែងពេបជ្រាយថា "យកពាក្យបាលីបាគូច្រើនម៉្លេះ រកភាពពុំកើត ចាំពុំបាន ពាក្យខ្មែរម្ដេចក៏មិនយកមកប្រើ

ដឹងជាឯងអី" ជាដើម ជាពាក្យទ្រគោះបោះបោកមិនសមរម្យដល់ក្រុមជំនុំវប្បធម៌ផង ខុសគន្លងដល់ជាតិខ្មែរផង ។

សូមអ្នកទាំងនោះគិតថា ពាក្យខ្មែរយើងតាំងពីបុរាណកាលមក តែងមានការលាយចំរុះគ្នា ដោយភាសាធំ ៣ គឺភាសាបាលី ១ ភាសាសំស្ក្រឹត ១ ភាសាខ្មែរ ១ ។ សាស្ត្រាបុរាណផ្សេងៗ មានរាមកេរ្តិ៍ នឹងកិច្ចការជាស្នាដៃអ្នកឧកញ៉ាវង្សាសារពេជ្ញទង់ជាដើម សឹងដេរដាសទៅដោយពាក្យបាលីនឹងសំស្ក្រឹតគ្រប់ទំព័រ តើអ្នកពេបជ្រាយទាំងឡាយនោះ កាលអានសាស្ត្រាទាំងនោះហើយ នឹងថាដូចម្តេចទៅទៀត, នឹងថាបុរាណប្រើពាក្យពិបាកស្តាប់ មិនដែលឮដែរឬ? ។

ដែលនឹងតាំងខ្លួនជាខ្មែរបាន តោងរក្សាកិត្តិយសខ្មែរឲ្យពេញបរិបូណ៌ កុំឲ្យមានពាក្យនិន្ទាថាខ្មែរមិនចេះខ្មែរ ។ ពាក្យដែលកើតថ្មី ឬពាក្យដែលយើងមិនស្គាល់ តោងសង្កាត់រៀនឲ្យចេះ ដើម្បីនឹងប្រើប្រាស់តាមការគួរទៅតាមកាលសម័យ ។ ធ្វើបែបនេះ ទើបឈ្មោះថាជាឧបាយនាំឲ្យចំរើនដល់អក្សរសាស្ត្ររបស់យើងផង ហើយជាកិច្ចលើកជាតិយើងឲ្យបានខ្ពស់មុខផង ដោយការមិននៅក្រោយគេក្នុងវង់ភាសានិយាយ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន នឹងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

## ការចងមិត្ត

មនុស្សយើងកើតមកក្នុងពិភពលោក ត្រូវតែប្រស្រ័យគ្នាទៅវិញទៅមករាប់រកចងបាច់គ្នាជាសម្ពន្ធមិត្រ ទើបអាចជួបប្រទះនូវជោគជ័យ មង្គលសួស្តី សេចក្តីសុខ-ចំរើនគ្រប់យ៉ាងបានដោយងាយ ទាំងការទ្រទ្រង់នូវជីវភាព ក៏នឹងអាចប្រព្រឹត្តទៅបានស្រួល, ប្រសិនបើយើងកើតមកនៅតែម្នាក់ឯង ដោយគ្មានការពឹងពាក់ប្រស្រ័យនឹងមិត្រភក្តិទេ វេលាដែលមានទុក្ខធុរៈភ័យអន្តរាយអ្វីមួយកើតឡើងដល់ខ្លួន យើងមិនអាចនឹងចៀសវាងឬរំដោះខ្លួនឲ្យរួចបានឡើយ ទាំងការចិញ្ចឹមជីវិតទៀតសោត ក៏មិនអាចប្រព្រឹត្តទៅបានដោយធូរស្រួលដែរ ។ ហេតុនោះក្នុងច្បាប់ព្រះពុទ្ធសាសនា ទើបមានដំបូន្មានជាច្រើនកន្លែងសំដែងសរសើរអំពីការចងមិត្រថាជាកិច្ចមួយដ៏ប្រសើរក្នុងលោក ។

អ្នកដែលរាប់អានគ្នាយ៉ាងជិតដិតស្និទ្ធស្នាល ហៅថាមិត្រ ។ នោះមានពីរពួកគឺ :

១ – កល្យាណមិត្ត មិត្រមានអធ្យាស្រ័យល្អ;

២ – បាបមិត្ត មិត្រមានអធ្យាស្រ័យអាក្រក់ ។

កល្យាណមិត្ត ចែកជា ៤ គឺ :

ក)– ឧបការោ មិត្រជួយទំនុកបំរុងដឹកនាំគាំទ្រឲ្យបានស្រួល;

ខ)– សមានសុខទុក្ខោ មិត្ររួមសុខរួមទុក្ខជាមួយគ្នា;

គ)– អត្ថក្ខាយី មិត្រណែនាំប្រាប់ពន្យល់សេចក្ដីចំរើន;

ឃ)– អនុកម្បកោ មិត្រមានសេចក្ដីអនុគ្រោះអាណិតអាសូរ ។

ឯបាបមិត្តចែកជា ៤ ដែរ គឺ :

ក)– អញ្ញទត្ថុហរោ មិត្រគិតតែចង់បានទ្រព្យសម្បត្តិអំពីមិត្រភក្តិ;

ខ)– វចីបរមោ មិត្របានតែសំដី (ល្អតែមាត់);

គ)– អនុប្បិយភាណី មិត្រប៉ុនប៉ិនិយាយអែបអបស្រែបតាម;

ឃ)– អបាយសហាយោ មិត្រដឹកនាំឲ្យវិនាសហិនហោច ។

ព្រះបរមគ្រូជាម្ចាស់លោក ទ្រង់ហាមឃាត់មិនឲ្យបុរសបុគ្គលទៅសេពគប់គប់ប្រែសញ្ញារាប់រកសមគំនិតស្និទ្ធស្នាលនឹងបាបមិត្រឡើយ ព្រោះជាហេតុនាំឲ្យកើតសេចក្ដីវិនាសត្រូវចំពូក, ត្រូវចៀសវាងឲ្យឆ្ងាយអំពីបាបមិត្រនោះដូចមាន់ខ្លាចសត្វខ្លែងដូច្នោះ ។ ទ្រង់ណែនាំឲ្យសេពគប់

ចង់ស្ពានមេត្រីតែនឹងកល្យាណមិត្ត ព្រោះជាផ្លូវហូរមកជានិច្ចនូវសេចក្តីចំរើនគ្រប់យ៉ាង ។ សូមនាំរឿងមហាឧក្កសជាតកជាសេចក្តីសង្ខេបមកជានិទស្សន៍ដូចតទៅនេះ ។

ក្នុងអតីតកាល កាលដែលព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុង-ពារាណសី, ពួកអ្នកស្រុកបច្ចន្តគ្រាម ជាអ្នកចូលចិត្តក្នុងការបរបាញ់ តែងប្រមូលចងបាច់គ្នាជាពួកជាក្រុមទៅនៅក្នុងទីដែលសម្បូរសត្វព្រៃ ហើយក៏ស្វះស្វែងរកសម្លាប់ម្រឹគនឹងបក្សីជាដើម នាំយកសាច់មកចិញ្ចឹមគ្រួសារជាធម្មតា ។ នៅក្បែរស្រុករបស់ជនទាំងនោះ មានជាស្រះមួយដ៏ធំទូលាយ ។ នៅជិតស្រះនោះឯងមានសត្វទាំង៥ អាស្រ័យនៅគឺ: ខ្លែងឈ្មោលនៅខាងត្បូង, ខ្លែងញីខាងលិច, រាជសីហ៍ខាងជើង, អកខាងកើត, អណ្តើកនៅត្រង់ដីទួលចំកណ្តាលស្រះ ។ កាលនោះខ្លែងឈ្មោលទៅនិយាយសុំខ្លែងញីធ្វើជាប្រពន្ធតាមប្រវេណីសត្វបក្សី ។ ខ្លែងញីសួរថាដែលអ្នកមកចង់បានខ្ញុំជាប្រពន្ធនេះ តើអ្នកមានមិត្រសំឡាញ់ឬទេ? ។ ខ្លែងឈ្មោលតបថា មិនមានមិត្រសំឡាញ់ទេ ។ ខ្លែងញីក៏ប្រាប់ទៅវិញថា ត្រូវអ្នករកចងមិត្រសំឡាញ់ឲ្យបានច្រើនគ្នាសិន ទើបខ្ញុំព្រមទទួលយកអ្នកធ្វើជាប្តី ហើយពន្យល់ខ្លែងឈ្មោលឲ្យទៅសុំចងស្ពានមេត្រីនឹងសត្វទាំង៣គឺ អក, រាជសីហ៍នឹងអណ្តើក ។ ខ្លែងឈ្មោលបានស្តាប់ពាក្យនោះហើយ ក៏ទៅសូមធ្វើជាមិត្រមេត្រីនឹងសត្វទាំងនោះបានសម្រេច

ដូចបំណងមែន ៗ គ្រានោះ ខ្ញុំទាំងពីរបានព្រមព្រៀងគ្នាជាប្ដីប្រពន្ធ ហើយទៅធ្វើសំបុកទុកពងលើចុងកុម្ពមួយដើម ត្រង់ដទួលកណ្ដាលស្រះនោះឯង ៗ លុះចំណេរចិរកាលតមក ខ្ញុំញីឈ្មោលក៏បានកូនពីរ ៗ ក្នុងថ្ងៃមួយ ពួកអ្នកស្រុកបបួលគ្រាម ដើរកេបរបាញ់សត្វក្នុងព្រៃ ឥតបានសត្វអ្វីមួយសោះ ដល់ពេលយប់ ក៏នាំគ្នាចុះទៅដេកក្រោមដើមកុម្ពកណ្ដាលស្រះនោះ មិនយូរប៉ុន្មានត្រូវមូសខាំទះញាប់ដៃគ្រប់គ្នា អត់ទ្រាំមិនបាន ក៏តាំងដុំដែកភ្លើងបង្កាត់ភ្លើងបង្ហុយផ្សែងបង្អើលមូស ៗ ផ្សែងភ្លើងហុយខ្លាំងធ្លូលឡើងទៅដល់សម្បុកខ្ញុំលើចុងកុម្ព; កូនខ្ញុំដែលនៅក្នុងសម្បុកមិនទាន់ដុះស្លាបល្មមហើររួចនៅឡើយ, កាលផ្សែងហុយមកប៉ះត្រូវដូច្នោះក៏យំស្រែករំពង ៗ ដៃអ្នកបាទទាំងនោះ ឮសូរសំឡេងកូនសត្វក៏មានសេចក្ដីត្រេកអរណាស់ ដាស់គ្នាឲ្យក្រោកឡើងជួយចងគប់កាន់ទ្រោលបំភ្លឺឡើងទៅយកកូនសត្វមកដុតស៊ី ៗ ខ្ញុំញីឮសូរសំដីជនទាំងនោះហើយក៏និយាយនឹងខ្ញុំឈ្មោលថា ពួកអ្នកជនបទទាំងនេះចង់គប់ភ្លើងប្រាថ្នានឹងឡើងមកយកកូនយើងទៅស៊ីជាប្រាកដ; ដូច្នេះ, សូមអ្នកទៅឲ្យដំណឹងជាប្រញាប់ដល់អកជាមិត្តសំឡាញ់យើង ដ្បិតយើងមានភ័យអាសន្នមកដល់ហើយ ៗ ខ្ញុំឈ្មោលក៏ស្ទុះម្នីម្នាទៅប្រាប់អកតាមដំណើរ ៗ អកក៏ព្រមជួយយកអាសាហើយបញ្ជូនខ្ញុំឈ្មោលឲ្យប្រញាប់ប្រញាល់ទៅប្រាប់ខ្ញុំញីជាមុនចុះ, ខ្លួនឯងនឹងទៅតាមក្រោយ

គន្លូវ ៗ វេលាដែលទៅដល់ភ្លាម, អកទំលើបុងឈើមួយក្បែរដើមកុម្ព នោះចាំសង្កេតមើលដើរការពួកវា ៗ ក្នុងខណៈដែលបុរសម្នាក់កំពុងកាន់គប់ភ្លើងឡើងតើមៗ ទៅជិតដល់សម្បុក, អកតាំងមុជទៅក្នុងស្រះឲ្យទឹកស្លាបជោក ហើយបៀមទឹកពេញមាត់ផង រួចហើយក៏ហើរមកទទះស្លាបព្រួសទឹកស្រោចលត់គប់ភ្លើងនោះឲ្យរលត់សូន្យឈឹង ៗ ម្នាក់កាន់គប់ឡើងទៅទៀត អកលត់ឲ្យរលត់ទៀតដែរ ៗ កាលប្រឹងលត់ភ្លើងដោយឧបាយនេះដរាបដល់ពាក់កណ្តាលអធ្រាត្រ, អកនឿយណាស់រងាញ័ររួញក្រពះក្រហាមក្អកអស់ ៗ ខ្វែងញីឃើញអកនឿយដូច្នោះ,ក៏និយាយនឹងខ្វែងឈ្មោលឲ្យទៅប្រាប់អកឲ្យឈប់សម្រាកសិន កុំឲ្យយ៉ាប់ពេកហើយឲ្យហួសទៅឲ្យដំណឹងដល់អណ្តើកជាប្រញាប់ ៗ ខ្វែងឈ្មោលបានធ្វើតាមពាក្យប្រពន្ធហើយទៅពឹងអណ្តើកឲ្យមកជួយស្រោចស្រង់ផង ៗ អណ្តើកទទួលភារៈដោយសេចក្តីស្ម័គ្រចិត្តឥតរួញរា ៗ គ្រានោះ កូនអណ្តើកនៅជាក់ក្បែរទីនោះ បានឮឪពុកនិយាយឆ្លើយឆ្លងជាមួយនឹងខ្វែងដូច្នោះ, ក៏តាំងក្រោកឡើងករក្រុស ៗ ទៅជិតឪពុក ហើយនិយាយថា "សូមឪពុកនៅស្ងៀមចុះ, ទុកភារៈនេះឲ្យកូនវិញ, ខ្ញុំសុំធានាអះអាងទៅជួយការពារកូនខ្វែងជំនួសឪពុក" ៗ អណ្តើកជាឪពុកតបថា "នៃកូន ការដែលកូនត្រូវតែធានាសុំខ្លួនដោះទុក្ខធុរៈផ្សេង ៗ ជំនួសឪពុកនេះឃើញថាត្រូវតាមគន្លងច្បាប់របស់សប្បុរសមែនហើយ, ប៉ុន្តែ ណ្ហើយចុះ កូនឯង

កុំបាច់ព្រួយក្នុងរឿងនេះ ។ មនុស្សទាំងនោះមុខជានឹងមិនខាបកូនទេ ព្រោះកូនឯងមាឌតូចណាស់ ក្រែងវាចាប់ហុតស៊ីទៅ, ទុកឲ្យឪពុកវិញ ទើបពួកវាញញើតព្រោះឪពុកមាឌសម្បើម ។

អណ្តើក លុះឃាត់កូនយ៉ាងនេះហើយ ទើបទៅយ៉ាងប្រញាប់ ចុះទៅក្នុងស្រះបារកក់ទឹងសាកយយកមកលត់ក្អក់ក្អើងលើកោះនោះ ។ ចំណែកពួកអ្នកជនបទបានឃើញអណ្តើកធំសម្បើមដូច្នោះ ក៏និយាយគ្នាដោយសេចក្តីត្រេកអរថា "រ៉ឺយកូនយើង, កុំរវល់នឹងអាកូនខ្ចងល្អិតល្អោចនោះ, នាំគ្នាមកលេងអណ្តើកធំឯណោះវិញ ព្រោះយើងបានតែមួយនេះល្មមឆ្អែតទាំងអស់គ្នាតែម្តង" ។ ដោយមិនដឹងជាធ្វើដូចម្តេចឲ្យស្លាប់ក្អាម កុំឲ្យអណ្តើកវារចុះទឹកទាន់ ពួកអ្នកទាំងនោះ ក៏ស្រាតសំពត់មកចងក្របួចធ្វើជាថង់រួចយកទៅវេចខ្ចប់អណ្តើក ហើយនាំគ្នាដែងទាញទប់ទុក; ប៉ុន្តែទាញមិនឈ្នះសោះ ដល់ទីបំផុត ជ័យជំនះត្រូវបានទៅអណ្តើកវិញ អណ្តើកអូសហូតដល់ទឹកជ្រៅ ហេតុតែលោភចង់បានអណ្តើក អ្នកទាំងនោះ ស៊ូប្រថុយមុជទៅតាមទាល់តែឈ្លក់ទឹកហើយផឹកទឹកប៉ោងពោះទាំងអស់គ្នាទើបឡើងមកវិញ រងាញ័រមាត់ណ្តំថាម៉ុប៉ប៉ប់, ងាកទៅរកក្អក់ក្អើងត្រូវអណ្តើកលត់អស់រលីង, ណាមួយសំពត់ស្លៀកក៏បានទៅអណ្តើកបាត់អស់ទៅ, នាំគ្នាឱបដៃកំព្រានៗ សំឡឹងមើលមុខគ្នាព្រឹះៗ ហើយនិយាយថា "ណ្ហើយចុះ, ចាំថ្ងៃរះឡើងសិមយើងឡើងយកកូនខ្ចង

ស៊ីឲ្យបាន" ។ ខ្វែងញីឮដូច្នោះ ក៏ប្រើខ្វែងឈ្មោលឲ្យទៅតឹងកជសីហ៍ទៀត ។ ក្រោយដែលបានទទួលពាក្យខ្វែងដោយសេចក្ដីស្មោះត្រង់រួចហើយ, កជសីហ៍ ដើរតំរង់ទៅរកដើមកុម្ពនោះ ។ មនុស្សទាំងអស់នោះ បានឃើញកជសីហ៍កំពុងដើរឆ្ពោងៗ មក, ក៏តាំងភ័យតក្កម៉ាពន់ប្រមាណគេប្រកស្មើរមិនទាន់, បាតជើងសព្រាតយកតែព្រះអាយុហើយទៀតនិយាយគ្នាបណ្ដើរផងថា "នេះហៅចំជាចំឡែកហើយរ៉ុយ, មុនដំបូង, អកលួតគប់ក្អែងយើង, តមកទៀត អណ្ដើកអួសយើងទម្លាក់ទឹកឲ្យឈ្ងក់កខក់ហើយប្រទាញយកទាំងសំពត់យើងអស់ទៅ, ឥឡូវនេះកជសីហ៍មកសម្លាប់យើងទៀតហើយ" ។ កជសីហ៍ទៅដល់គល់កុម្ពឥតឃើញមនុស្សម្នាក់សោះ ។ ខណៈនោះ, អក, អណ្ដើកនឹងខ្វែងចូលទៅរកកជសីហ៍ៗ ពន្យល់នូវអានិសង្សមិត្រដល់សត្វទាំងនោះរួចហើយឲ្យឱវាទតទៅទៀតថា "ចាប់តាំងពីថ្ងៃនេះតទៅ អ្នកទាំងអស់គ្នាត្រូវរក្សាមិត្តធម៌ឲ្យថិតថេរមុតមាំ កុំបីប្រហែសធ្វេសឡើយ" ។ សត្វទាំងនោះទទួលស្ដាប់ឱវាទនោះហើយ ក៏លាគ្នាទៅកាន់លំនៅរៀងៗខ្លួន ។

ខ្វែងញីទំសំឡឹងមើលកូនដែលមានមុខស្រស់ញញឹម ហើយចរចានឹងខ្វែងឈ្មោលថា "យើងបានរក្សាកូនឲ្យរស់រានមានជីវិតដោយសួស្ដីនេះព្រោះអាស្រ័យកល្យាណមិត្រទាំងឡាយ; បុគ្គលអ្នកប្រាថ្នាសេចក្ដីសុខគួរតែមានមិត្រសំឡាញ់ច្រើន ។ យើងអាចកំចាត់នូវខ្មាំងបាន ដោយ

សារកំឡាំងមិត្រ  ហើយបានមូលមិត្រកែកាយជាមួយនឹងកូនទាំងឡាយ, ដូចជាបុគ្គលដែលមានគ្រឿងក្រោះពាក់  អាចការាំងនូវព្រួញទាំងឡាយ បានដូច្នោះឯង" ។

សត្វជាសម្លាញ់នឹងគ្នាទាំងនោះ  រក្សាមិត្តធម៌ដរាបដល់អស់ជីវិត រៀងៗខ្លួនទៅហោង ។

រឿងដែលបាននិយាយមកដោយសង្ខេបនេះឯង ជាគ្រឿងនិទស្សន៍ ដោយច្បាស់លាស់ថា  មនុស្សនៅក្នុងសង្គម, ក្នុងស្រុក, ក្នុងប្រទេសនីមួយៗ គួរតែមានមិត្តច្រើន  ហើយគប្បីចងបាច់ព្រមព្រៀងស្មោះសរគ្នាយ៉ាងមុតមាំ  ទើបអាចជួបប្រទះសេចក្តីសុខ-ចំរើនបានដោយងាយ សមគួរតាមកាល.ទេស: ។

ស្រី - អ៊ី

---

ន ភជេ បាបកេ មិត្តេ  ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ  ភជេថ បុរិសុត្តមេ ។

កុំគប្បីសេពគប់បាបមិត្ត  កុំគប្បីសេពគប់បុរសថុនអន់
គប្បីសេពគប់កល្យាណមិត្ត  គប្បីសេពគប់បុរសឧត្តម ។

ធម្មបទ

# បទពិចារណាពីសែនក្រុងពាលី

ក្រុងពាលីជាតិជាអ្វី? នៅឯណា? មានគុណធម៌ដូចម្ដេច? អ្នកកាន់ព្រះពុទ្ធសាសនាត្រូវគោរពបូជាដល់ឈ្មោះនេះដែរឬទេ? ។

តាមដែលដឹងមក រឿងក្រុងពាលីដែលពិតប្រាកដ គឺជារឿងក្រៅព្រះពុទ្ធសាសនាទាំងស្រុង គ្មានទាក់ទាមដោយព្រះពុទ្ធសាសនាសូម្បីបន្តិចបន្តួចសោះ ។ ហេតុដែលខ្ញុំនាំមកសំដែងក្នុងទស្សនាវដ្ដីនេះ ដោយខ្ញុំតែងឃើញពួកអ្នកកាន់ព្រះពុទ្ធសាសនាជាច្រើននាក់រមែងបូជាដល់ក្រុងពាលី ដែលហៅថា "សែនក្រុងពាលី" ក្នុងវេលាដែលគេធ្វើពិធីមង្គលផ្សេងៗ និងក្នុងពេលធ្វើបុណ្យកុសលផ្សេងៗ ខ្វះទៀតជាញឹកញយ ។ កាលសួរដេញដោលថា ការសែនក្រុងពាលីនោះ មានប្រយោជន៍ដូចម្ដេច? ក៏បានទទួលតបអំពីលោកអាចារ្យចាស់ៗ ថាសែនទៅសុំឱ្យសុខសប្បាយ ព្រោះក្រុងពាលីជាម្ចាស់ទឹកដី ។ អ្នកតបបែបនេះមានចំនួនច្រើនណាស់ ។

តែខ្ញុំបានសួរលោកហោរាចារ្យធំ ១ នាក់ដែលលោកតែងធ្វើពិធីនេះឱ្យគេជាញឹកញយ លោកតបថា: ហេតុដែលគេសែនក្រុងពាលី ដោយគេត្រូវការរំលឹកដល់គុណឧបការៈរបស់ក្រុងពាលី ព្រោះមានរឿងរ៉ាវក្នុងសម័យព្រេងនាយថា មានទេវតា ១ អង្គនាមព្រះបាទកោញ្ចលាំងនៅឯឋានសួគ៌បានចាត់បុត្រឈ្មោះពាលី គឺក្រុងពាលីនេះឯងឱ្យមកសោយរាជ្យគ្រប់គ្រងមនុស្សលោកនៅក្នុងជម្ពូទ្វីប គឺដែនសណ្ឋានក្នុងបច្ចុប្បន្ន ។ ក្រុង

ពលីបានគ្រប់គ្រងមនុស្សលោកដោយទសពិធរាជធម៌យ៉ាងល្អ បានធ្វើគុណូបការៈដល់ពួកមនុស្សជាអនេក ៗ ដោយហេតុនេះកាលក្រុងពលីសុគតទៅហើយ ទើបគេសែនរំលឹកដល់គុណលោក ៗ លោកហោរនោះបានបញ្ជាក់ថា រឿងក្រុងពលីនេះមានក្នុងគម្ពីរត្រៃលោកវិត្ថារ ៗ

សេចក្ដីតបនេះ បើស្ដាប់យ៉ាងគ្រើមៗ ឃើញហាក់ដូចជាមានដំនឿខ្វះដែរ តែបើដេញដោលស្រាវជ្រាវរកគោលកស្ដាង ដ៏ពិតប្រាកដទៅត្រឡប់ជាទទេទៅវិញ, ព្រោះថា តាមធម្មតាទេវតាមែងនៅដោយពួកទេវតា បើទេវតាណាបានជាស្ដេច ដូចយ៉ាងព្រះឥន្ទ្រ ក៏មានសិទ្ធិគ្រប់គ្រងតែពួកទេវតាផងគ្នា ទេវតាមិនដែលផ្សាយឥទ្ធិពលមកគ្រប់គ្រងមនុស្សលោកក្នុងវេលាណាបន្តិចទេ ទេវតាមិនបេះធ្វើនយោបាយរុករានយកដែនរបស់មនុស្ស ទៅធ្វើជាអាណានិគមរបស់ខ្លួនទេ បើទុកជាយើងយកប្រវត្តិសាស្ត្រ ឬគម្ពីរណាដែលគេសំគាល់ថាត្រឹមត្រូវមកត្រដាងមើល ក៏គង់មិនប្រទះក្នែកដែរ ៗ ក្នុងពួកប្រវត្តិសាស្ត្រ, ប្រវត្តិសាស្ត្រជម្ពូទ្វីបមានអាយុវែងជាងគេបំផុតគឺរបាក្សត្រីយ៍ (បាពិក្សត្រីយ៍) សុរិយវង្សនិងចន្ទ្រវង្ស ដែលចារិកព្រះនាមក្សត្រីយ៍ទុកជាភាសាសំស្ក្រឹត រាប់រៀងតាំងពីសម័យព្រះរាមឬមុននេះទៅទៀត ក៏គ្មានប្រាកដថា ទេវតាឈ្មោះពលីមកសោយរាជ្យគ្រប់គ្រងមនុស្សលោកដែរ បើយើងយកគម្ពីរសាសនាមកមើល ដូចយ៉ាងគម្ពីរខាងសាសនាព្រាហ្មណ៍ក្ដី គម្ពីរខាងព្រះពុទ្ធ

សាសនាក្តី  ក៏គង់មិនប្រទះរឿងទេវតាឈ្មោះដូច្នេះ  ចុះមកសោយរាជ្យ
គ្រប់គ្រងមនុស្សដែរ ។ ត្រង់ខដែលអាងថា  មានក្នុងគម្ពីរត្រៃលោកវិត្ថារ
នោះ  យើងត្រូវពិនិត្យតទៅទៀតថា  រឿងនេះមានក្នុងគម្ពីរនោះមែនឬទេ?
អ្នកតែងគម្ពីរឈ្មោះអី  តែងពីសតវត្សប៉ុន្មាន?  អ្នកនោះជ្រួតជ្រាបប្រវត្តិ-
សាស្ត្ររបស់ត្រៃលោកបានដោយកលអ្វី? ។  គម្ពីរសារត្ថសង្គហៈដែល
ព្រះនន្ទាចារ្យតែងក៏មាននិយាយដល់រឿងត្រៃលោកខ្លះដែរ  តែគ្មានរឿង
ក្រុងពលីនៅក្នុងគម្ពីរនោះទេ  អ្នកតែងគម្ពីរត្រៃលោកវិត្ថារបានរឿងនោះ
ពីណាទៅនិយាយ ។

១ទៀត  បើក្រុងពលីបានមកគ្រប់គ្រងអ្នកជម្ពូទ្វីបមែន  ក៏គួរតែអ្នក
ដែលនៅក្នុងជម្ពូទ្វីបសែនរំលឹកគុណទៅចុះ ពួកយើងដែលនៅក្រៅជម្ពូទ្វីប
គ្មានទាក់ទាមអ្វីផងទេ  ហេតុម្តេចក៏ប្រឹងសំដែងកតញ្ញូខ្លាំងម៉្លេះ  ត្រង់ស្តេច
ចក្រពត្តិដែលកើតក្នុងចន្លោះពុទ្ធកាល  ជាអ្នកមានអំណាចគ្រប់គ្រងផុត
ផែនដីទាំងមូល  ជាអ្នកទ្រង់ទសពិធរាជធម៌យ៉ាងពិតប្រាកដជាងក្សត្រិយ៍
សាមញ្ញនេះ  រាប់រយភាគ  ដូចមានសំដែងក្នុងគម្ពីរពុទ្ធសាសនារបស់
ពួកយើងស្រាប់  ហេតុម្តេចក៏ពួកយើងមិននឹកនាសែនទៅថ្វាយខ្លះផង ។

ក្រៅពីដែលសួរផ្ចាល់មាត់ ខ្ញុំបានប្រទះតម្រា១ ហៅថា "តម្រាសែន
ក្រុងពលី" គេបានដាក់ស៊ឹករឹត  ជាតម្រារបស់ខ្មែរយើង; តម្រាបែបនេះ
ខ្ញុំស្មានថាគង់មាននៅតាមវត្ត  និងនៅតាមផ្ទះដទៃទៀតជាច្រើន ។

សេចក្តីកំណត់ត្រានោះថា: សម័យមួយព្រះពុទ្ធអង្គបានទៅអួតក្អាល់នឹងក្រុងពលីថា ទ្រង់ឈានតែ ៣ ជំហាន ឲ្យផុតផែនដីទាំងមូល ៗ ក្រុងពលីមិនជឿសង្ឃឹមថានឹងឈ្នះ ក៏ព្រមក្អាល់ផង; ឯរបស់ក្រយាក្អាល់មានអ្វីខ្លះ មិនបានសន្យាគ្នាតាំងទុកជាមុន ៗ លំដាប់នោះព្រះពុទ្ធអង្គតាំងលើកព្រះបាទឈានទៅបានតែ ២ ជំហានក៏ឈប់ទៅ មិនឈានតទៅទៀត ៗ ព្រោះហេតុអ្វីទ្រង់មិនឈានជំហានទី ៣ តទៅទៀតឲ្យឃើញថាផុតមែនឬមិនផុត ឬទ្រង់ឃើញថាផែនដីនៅសល់វែងណាស់មិនអាចនឹងឈានឲ្យផុតទៅបាន តោងញ៉មចាញ់ក្រុងពលីទៅចុះ ក៏មិនឃើញមានពោលដល់ ស្រាប់តែថាព្រះពុទ្ធអង្គចាញ់ក្រុងពលី ៗ ទារយកតែត្រូវតែចង(១) ព្រះពុទ្ធអង្គគ្មានតែត្រូវតែចងនឹងឲ្យក្រុងពលី ទើបទ្រង់អនុញ្ញាតឲ្យពួកឧបាសកឧបាសិកាអ្នកដែលនឹងធ្វើកងការកុសល ឬនឹងធ្វើពិធីមង្គលទាំងពួង គប្បីសែនតែទៅឲ្យក្រុងពលីផងចុះ ៗ ហេតុនេះទើបមានទំនៀមសែនក្រុងពលីរាបដល់សព្វថ្ងៃនេះ ៗ រឿងនេះនឹកៗទៅក៏គួរឲ្យអស់សំណើច អ្នកណាហ្ន៎ ក្លាហានដល់ទៅតែងរឿងបែបនេះទុកមកមិនរអែងដល់គេអ្នកចេះដឹងឯទៀតផងសោះ ៗ

កង្ករណីនេះ ខ្ញុំបានស្រាវជ្រាវទៅប្រទះរឿងក្រុងពលី ១ យ៉ាងទៀត រួមនៅក្នុងរឿងនារាយណ៍អវតារ គឺរឿងព្រះនារាយណ៍បែងភាគ

---

១ តាមទំនៀម គេសែនដោយតែយញ្ញ ៗ

[library stamp]

១០ គ្រា, រឿងនេះជារបស់ព្រាហ្មណ៍ពួកវៃស្ណវនិកាយ គឺពួកអ្នកគប់អានព្រះវិស្ណុជាព្រះធំ, ចូរមើលត្រង់រឿងបែងភាគគ្រាទី ៥ ដែលហៅឈ្មោះ "វាមនាវតារ" រឿងនេះគេទុកដាក់ជារឿងដើមរបស់ក្រុងពលី ។ សេចក្ដីក្នុងរឿងនេះថា: - មានស្ដេចបិសាច ១ ឈ្មោះពលី (ដែលយើងហៅថាក្រុងពលី តែមិនប្រាកដជានៅទីឋានណា (មើលរូបភាពដែលគេគូរប្ក គេផ្ទាក់ទុក ឃើញប្រហែលៗ ជាយក្ខ) មានប្រាថ្នាចង់បានបុណ្យ ឲ្យខ្លាំងពូកែឈ្នះឈ្នានអស់ទេវតានិងមនុស្សទាំងឡាយ ក៏ទៅបំពេញតបៈថ្វាយព្រះឥសូរ ដើម្បីសុំពរឲ្យមានបុណ្យ, បំពេញតបៈទៅមិនយូរប៉ុន្មាន ព្រះឥសូរឈ្វេងយល់ថា មានសេចក្ដីស្មោះស្ម័គ្រភក្ដីចំពោះព្រះអង្គពិតហើយ ក៏ទ្រង់ប្រទានពរឲ្យជាអ្នកមានបុណ្យដូចពោលហើយ ។

ក្រុងពលីកាលបានពរអំពីព្រះឥសូរហើយ ក៏តាំងតែហោះហើរទៅក្នុងឋានមនុស្សលោក និងទេវលោក អួតបុណ្យក្អេងក្អាងយ៉ាងក្រុងរាពណ៍ ត្រាច់រុករានបៀតបៀនមនុស្សនិងទេវតា ក៏ហែងចាប់ពួកក្រមុំទេវតាជាញឹកញាប់ គ្មានអ្នកណាមួយអាចតស៊ូបាន ។ ពួកទេវតាបានសេចក្ដីអាម៉ាស់មុខ និងក្ដៅក្រហាយខ្លាំងណាស់ ទើបនាំគ្នាទៅទូលព្រះឥសូរដ៏ជាគ្រូរបស់ក្រុងពលី សុំឲ្យកម្រាបក្រុងពលីចេញ ។ ព្រះឥសូរបថ្លថា គាំបិតបិតដងឯងវាមិនកើតទេ ទេវតាអើយ; តែទ្រង់អំពាវសុំឲ្យ

២ រឿងនេះខ្ញុំបានរៀបរៀងចុះក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៤៥ ។

ព្រះនារាយណ៍ជួយកម្រាប ព្រោះព្រះនារាយណ៍ជាព្រះខាងផ្លូវសឹកសង្គ្រាម ឈ្មោះថាការច្បាំងតស៊ូគ្នាហើយ ក្នុងត្រៃលោកគ្មានអ្នកណាមួយច្បាំងឈ្នះទេ ។

ព្រះនារាយណ៍ក៏ទទួលយកអាសា, ហើយក៏បែងភាគព្រះអង្គជាវាមន គឺជាព្រាហ្មណ៍តូចតឿទាបខ្លងគម ត្រាច់សួរស្វែងទៅជួបនឹងក្រុងពលី, កាលជួបហើយ ក៏លើកដៃប្រណម្យព្រមទាំងបញ្ចេញវាចាថា "បពិត្រលោកដ៏ជាម្ចាស់ទឹកដី ខ្ញុំសូមដីប្រវែង ៣ ជំហានសម្រាប់អាស្រ័យនៅ" ។ ក្រុងពលីគិតថា អាកន្ទ្រើយនេះវានឹងឈានបានប្រវែងប៉ុន្មាន ហើយក៏ព្រមឲ្យតាមសុំ ។ លំដាប់នោះ វាមន ក៏ប្រារព្ធឈានវាស់យកដី គឺឈានជំហានទី ១ ផុតឋានមនុស្សលោកទាំងមូល ជំហានទី ២ ផុតឋានសួគ៌ទាំងអស់ ជំហានទី ៣ ក៏ជាន់លើក្បាលក្រុងពលី ធាក់បង្អប់ទៅក្នុងដីឆ្ងាយទៅដល់ឋានបាតាល ហើយទ្រង់ក៏ដកព្រះបាទចេញត្រឹមនោះ ដោយទ្រង់គិតអាណិតថា នឹងធាក់ឲ្យកប់ជ្រៅជាងនេះទៅទៀតក៏បាន តែនឹងគ្មានទីអាស្រ័យនៅ ទ្រង់ដាក់កម្រិតអាជ្ញានិទេសថា ឲ្យក្រុងពលីនៅតែក្នុងឋានបាតាលប៉ុណ្ណោះ នឹងឡើងទៅឋានដើមវិញពុំបាន ហើយត្រាស់ឧបាយដែលនឹងឲ្យរួចទោសថា ទៅក្នុងអនាគត ប្រសិនជាក្រុងពលីលះពុតព្យសបែបនោះចេញ ហើយតាំងចិត្តស្វាមិភក្តិចំពោះព្រះជាម្ចាស់ អាចនឹងឡើងទៅនៅឋានដើមវិញបាន ។

ក្រុងពលីកាលត្រូវនិរទេសទៅនៅឋានបាតាល  ក៏បាននូវសេចក្ដីក្រីក្រស្រេកឃ្លានពន់ពេកណាស់  ទើបពឹងឲ្យព្រះភូមិឡើងមកទូលព្រះនារាយណ៍  សូមសេចក្ដីអនុគ្រោះថា  ក្រុងពលីដែលទៅឯឋានបាតាលបាននូវសេចក្ដីអត់ឃ្លានជាយ៉ាងក្រៃពេក  សូមព្រះអង្គមេត្តាអនុញ្ញាតឲ្យពួកអ្នកធ្វើពិធីផ្សេងៗ សែនឧទ្ទិសទៅឲ្យខ្លះផង ។ ព្រះនារាយណ៍អាណិតក៏ទ្រង់អនុញ្ញាតតាមសុំ ។ នេះជារឿងការដើមរបស់ក្រុងពលី ។

កាលយើងស្ដាប់រឿងព្រះនារាយណ៍កម្រាបក្រុងពលីចប់ចុះហើយ យើងក៏អាចដឹងធុះទៅដល់រឿងដែលថា  ព្រះពុទ្ធអង្គក្នាល់ឈាន  ចាញ់ក្រុងពលី  នឹងដឹងដល់និស្ស័យចិត្តថ្លើមរបស់អ្នកតែងរឿងនោះយ៉ាងជាក់ស្ដែង  និយាយយ៉ាងខ្លីគឺថាអ្នកនោះឯងតែងបំភ័ន្តយករឿងព្រះនារាយណ៍ឈានកម្រាបក្រុងពលីនេះ  ទៅជារឿងព្រះពុទ្ធអង្គឈានក្នាល់ទឹងក្រុងពលីទៅវិញ ។ ដូច្នេះតើ. យើងជាពុទ្ធមាមក: នឹងសន្និដ្ឋានយកផ្លូវយ៉ាងណាជាប្រមាណ,  បុគ្គលដែលមានចរិយាយ៉ាងក្រុងពលីសមគួរឲ្យយើងបូជាដែរឬ? ។

ការដែលខ្ញុំសើរើយករឿងចំនៀមទម្លាប់ចាស់ៗ បែបនេះខ្លះមកនិយាយសម្រាប់សាធារណជន  ខ្ញុំស្មានថា  ដូចអេះត្រូវកន្ទួងរមាស់ក៏មានដូចអេះត្រូវកន្ទួងដំបៅក៏មាន  តែខ្ញុំសូមទទួលសារភាពថា  ការដែលលើកយកមកនិយាយជាថ្មីនេះ  ដោយមានបំណងនឹងនាំស្នើអស់លោកជា

ពុទ្ធមាមកៈជួយវិនិច្ឆ័យតទៅ ដើម្បីកុំឲ្យគេអុកបានថា **សត្វបពោធ ទំលើមែកពោទៅស៊ីឯផ្លែជ្រៃ** ។ ខ្ញុំគ្មានបំណងនឹងលុបលាងទំនៀមទម្លាប់ដែលធ្លាប់មានមកហើយទេ ឬមានចេតនាគិតនឹងបង្ខាតបង្ខូចបុណ្យកុសលផលប្រយោជន៍ដែលគេត្រូវបានក៏ទេដែរ សូមតែឲ្យជួយពិចារណារកហេតុផលប៉ុណ្ណោះ ។

ក្នុងទីបំផុតនេះ ខ្ញុំសូមបព៌ណាទុកថា បើលោកអ្នកឯណាបានប្រទះឃើញក្រុងពលីផ្សេងទៀត ដែលមានគោលគួរជឿបាន សូមមេត្តាឲ្យដំណឹងដល់ខ្ញុំផង ។

ឈឹម - ក្រសេម

---

សុនក្ខត្តំ សុមង្គលំ សុប្បភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលពពួកសត្វ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះ ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ, ទានដែលគេបានបូជាត្រូវទំនងចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងពេលនោះ ឈ្មោះថាជាគ្រឿងបូជាល្អ ។

ជយបត្តិ

# ដំណឹងការកសាងវត្តមួយនៅក្រុងព្រៃនគរ

យើងបានដំណឹងមកថា ពួកពុទ្ធបរិស័ទជាតិខ្មែរ ដែលខ្វាត់ខ្វាត់ចាកខេត្តផ្សេងៗ មានខេត្តត្រាវិញ ខេត្តឃ្លាំង ប៉ោលា នឹងស្វាយរៀងជាដើម ចូលទៅនៅក្នុងទីក្រុងព្រៃនគរ បានស្រុះស្រួលបបួលគ្នាសុំដីរាជការក្រុងនោះមួយកន្លែងកសាងវត្តព្រះពុទ្ធសាសនា ឲ្យឈ្មោះថា “វត្តចន្ទរង្សី” នៅវិថីអឺរយោដេវែរ ក្រុងព្រៃនគរ ។ វត្តនោះចាប់កំណើតបានពីរឆ្នាំហើយ មានកុដិតូចៗប្រក់ស្លឹកពីរខ្នង នឹងរោងឧបោ-សថកម្មួយខ្នងទៀត គេបាននិមន្តព្រះសង្ឃនៅគង់ចាំចំនួន ៤ អង្គ ។ ឯទីវត្តនោះបង្អៀតបង្អល់ពេក ពុទ្ធបរិស័ទក្រុងព្រៃនគរ កំពុងផ្តើមធ្វើបុណ្យផ្កាយកបច្ច័យទៅជាវដីជាប់គ្នាមួយកន្លែង ដើម្បីពង្រីកឲ្យបានទូលាយបន្តិច តែកំឡាំងធនធានស្តួចស្តើងពេក ទើបបានអំពាវនាវសុំឲ្យអ្នកកាន់ព្រះពុទ្ធសាសនាគ្រប់រូបជួយឧបត្ថម្ភផង ។

សមាគមមិត្តសាលាបាលី សូមសរសើរពួកពុទ្ធមាមកជននៅទីក្រុងព្រៃនគរ ដោយស្មោះត្រង់ដែលមានសទ្ធាជ្រះថ្លាដ៏បរិសុទ្ធ នឹងមានគំនិតល្អបានចំកសាងវត្ត ឲ្យកើតទុកជាកិត្តិយសដល់ព្រះពុទ្ធសាសនានឹងជាកេរ្តិ៍តំណែលខ្មែរដ៏ប្រសើរមួយកណ្តាលទីក្រុងប្រទេសគេ ហើយសូមសសោះអន្ទួងដល់ពួកពុទ្ធបរិស័ទ នៅប្រទេសខ្មែរសូមឲ្យទទួលស្គាល់នូវ “វត្តចន្ទរង្សី” នោះ ដោយការជួយជ្រោមជ្រែងឲ្យបានរឹងប៉ឹងជំហរតទៅ ។

សមាគមមិត្តសាលាបាលី

**អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបរិកជាតិ**

**អក្សរសាស្ត្ររលត់ ជាតិរលត់ ។**

# ប្រវត្តិព្រះមហាវិមលធម្ម ថោង

**(ដកស្រង់អំពីប្រវត្តិដែលព្រះឧត្តមមុនី អ៊ុំ - ស៊ូ បានរៀបរៀង ទុកខាងដើមសៀវភៅបរាភវសូត្រ)**

ព្រះមហាវិមលធម្ម នាមដើម ថោង នាមក្នុងភិក្ខុភាវៈជាព្រហ្មបណ្ឌិត, ជាតិខ្មែរ, បិតាឈ្មោះរ័តន៍ មានគោរម្យងារជាឧកញ៉ាពិភក្តិវាទី, មាតាឈ្មោះខាវ, ស្រុកកំណើតនៅភូមិកំពង់ផែក្រុងភ្នំពេញ ។

លោកកើតនៅថ្ងៃព្រហស្បតិ៍ ១៣ កើតខែចេត្រឆ្នាំកុរ បញ្ចស័ក ព. ស. ២៤០៥ (គ. ស. ១៨៦២) ។ លុះដល់អាយុបាន ១៧ ឆ្នាំ ក្នុងឆ្នាំខាលសំរឹទ្ធិស័ក បានបួសជាសាមណេរក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាមទៀង នៅវត្តឧណ្ណាលោមក្រុងភ្នំពេញ, លោកបានសិក្សាភាសាបាឡី - ព្រះត្រៃបិដកអំពីសំណាក់អាចារ្យជាច្រើន មានសម្តេចព្រះមហាសង្ឃរាជព្រះនាមទៀង នឹងលោកឧកញ៉ាសុធម្មមេធា រ៉ត ជាដើម ហើយបានធ្វើជាអាចារ្យបង្រៀនភាសាបាឡីដល់សិស្សទាំងឡាយតាំងពីនៅជាសាមណេរ ។ ក្នុងកំណត់អាយុ ២១ ឆ្នាំ នៅឆ្នាំមមីបញ្ចស័ក លោកបានបំពេញឧបសម្បទជាភិក្ខុក្នុងពទ្ធសីមាវត្ត

ខណ្ឌាលោម ។ ក្នុង គ.ស. ១៨៩០ បានឡើងសមណស័ក្តិជាព្រះគ្រូសង្ឃសត្ថា, បន្ទាប់មកទៀត បានឡើងជាបាឡាត់សង្ឃរាជ្ញ ។

ដល់ជន្មាយុ ៤១ ឆ្នាំ, លោកមានបំណងចង់បានសាស្ត្រាបាឡី ព្រះត្រៃបិដកអក្សរខ្មែរពីប្រទេសសៀម យកមកតំកល់ទុកនៅប្រទេសខ្មែរពន់ពេក ទើបចូលទៅថ្វាយបង្គំលាសម្តេចព្រះមហាសង្ឃរាជជាព្រះឧបជ្ឈាយ៍, ទ្រង់ក៏បានអនុញ្ញាតបើកឲ្យទៅដោយស្រួល, រួចហើយលោករៀបដំណើរចេញទៅនៅថ្ងៃ ៣ កើតខែអស្សុជឆ្នាំខាល ។ ឯដំណើរទៅប្រទេសសៀមក្នុងជាន់នោះលំបាកណាស់, ត្រូវទៅតាមផ្លូវទឹកខ្លះ ផ្លូវគោកខ្លះ អស់កាលជាយូរថ្ងៃទើបបានដល់ ។

កាលទៅដល់ប្រទេសសៀមហើយ, លោកបានទៅគង់នៅវត្តចក្រវត្តិរាជាវាសក្រុងបាងកក, បានទទួលសេចក្តីទំនុកបំរុងរាប់អានទឹងសេចក្តីសរសើរជាច្រើនអំពីឥស្សរជនទាំងឡាយ មានព្រះយ៉ាវុឌ្ឍិការទឹងក្រុមព្រះទំរង់រាជានុភាពជាដើម ។ លោកគង់នៅបាងកកបាន ១២ ខែ ក៏សូមថ្វាយព្រះពរលាក្រុមព្រះទំរង់រាជានុភាពវិលត្រឡប់មកប្រទេសខ្មែរវិញ, ទ្រង់បានសូមអង្វរឃាត់លោកជាច្រើនលើក ដើម្បីសូមឲ្យលោកគង់នៅទីនោះឲ្យបានយូរតទៅទៀត, ប៉ុន្តែលោកពុំព្រម ទើបទ្រង់ចាត់ចែងរៀបជូនដំណើរលោក ។ ទ្រង់បានចេញចុតហ្មាយ ១ ច្បាប់ប្រាប់ដល់អ្នករាជការតាមរយៈផ្លូវឲ្យជូនដំណើរលោកតៗទៅ តាំងពីក្រុងបាងកក

រហូតមកដល់បាត់ដំបងដែលជំនាន់នោះនៅក្នុងអំណាចរាជការសៀមនៅឡើយ ។ ដល់ទីបំផុត, លោកបានចូលមកដល់ក្រុងភ្នំពេញវិញ (បាននាំងនាំគម្ពីរដីកាផ្សេងៗ ជាច្រើនមកជាមួយផង?) ។

លុះដល់ គ. ស. ១៩០៣ ព្រះករុណាជាម្ចាស់ជីវិតព្រះបាទសម្ដេចព្រះនរោត្តម ទ្រង់ប្រោសព្រះរាជទានទីកជាគណៈ ងារជាព្រះមហាវិមលធម្មភឿនហ្វង ។ ដល់មកក្នុង គ. ស. ១៩១៤, ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ទ្រង់តាំងលោកឲ្យធ្វើជាចាងហ្វាងសាលាបាឡីជាន់ខ្ពស់ភ្នំពេញ ។ តមកទៀត, រាជការបានតាំងលោកជាក្រុមជំនុំសព្វវចនាធិប្បាយខ្មែរ ។

ព្រះមហាវិមលធម្ម ថោងបានទទួលគ្រឿងឥស្សរិយយសពីរាជការដូចខាងក្រោមនេះ ៖

- មណីសារាភ័ណ្ឌ (២៩ សីហា ១៩០៥)
- មេដៃយមាស (១៩ កុម្ភ ១៩១៧)
- អូហ្វីស្សេរដាកាដេមី (៣០ មិថុនា ១៩២២) ។

ឯចំណេះវិជ្ជាដែលលោកបានចេះដឹងនោះ គឺភាសាបាឡី, អក្សរភាសាសៀម, អក្សរ-ភាសាលាវស្ទាត់ដូចភាសាខ្មែរដែរ, អក្សរភូមាលង្កា មើលសរសេរជាបាឡីបាន ។

កិច្ចការជាស្នាដៃដែលលោកបានប្រែនិងរៀបរៀងទុកគឺ អនាគារវិន័យ, អគារវិន័យ, បព្វជ្ជាខន្ធកសង្ខេប, ឧបោសថកថា, កាលាមសូត្រ, បរាភវសូត្រ, អក្ខរកិច្ចានសព្ទ, គម្ពីរវុត្តោទ័យ ។

ព្រះមហាវិមលធម្ម ថោង ជាអ្នកប្រាជ្ញ ១ រូបដែលយកព្រះទ័យទុកដាក់ជាទីបំផុត ក្នុងការពង្រីកផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរឲ្យបានចំរើនលូតលាស់តាមកាលសម័យ ។ លោកបានបំពេញករណីយកិច្ចតាមនាទីរបស់លោកឥតធុញទ្រាន់ ដរាបមកដល់ជន្មាយុគំរប់ ៦៥, ក្នុងឆ្នាំថោះខែអាសាឍ ៤ រោច (១៨-៧-២៧) នៅវេលាយប់ លោកក៏ចាប់មានរោគាពាធជាទម្ងន់ បណ្ដាលទៅជាទល់ចង្អោរអត់អាហារ ចំនួន ១៥ ថ្ងៃ ទើបលោកទទួលអនិច្ចធម្មទៅក្នុងវេលារាត្រីម៉ោង ២ និង ១០ នាទី នៅថ្ងៃអង្គារ ៤ កើតខែស្រាពណ៍ឆ្នាំថោះនពស័កព.ស. ២៤៧០ (២-៨-២៧) នៅកុដិរបស់លោកក្នុងវត្តឧណ្ណាលោមក្រុងភ្នំពេញ ។

---

"នែក្មេងរាល់គ្នា! ឯងកុំធ្វើបាបឆ្កែនេះ ដ្បិតវាជាសត្វកំព្រាអនាថាគ្មានទីសង្ឃឹម, វាមានសេចក្ដីស្រេកឃ្លានវេទនា ទទួលរងទុក្ខសុខដូចមនុស្សយើងដែរ, ប្លែកគ្នាតែត្រង់រូបរាងប៉ុណ្ណោះទេ ឯងរាល់គ្នាកុំស្មានថា ធ្វើបាបបន្តិចបន្តួច មិនបានបាបនោះឡើយ" ។

ព្រះមហាវិមលធម្ម ថោង

# មរណៈនៃសត្វសេះ

តាមផ្លូវក្រហូងក្តៅស្ទើរឆេះ រទេះសេះមួយចំអូសនាំ
អង្ករប្រាំបាវប្រែកយ៉ាងមាំ ស៊ូទ្រាំទាញទង់ទាំងថ្ងៃត្រង់ ។
ស្ងប់ស្ងាត់សត្វសេះមិនបេះបង្វ កាសូរអ៊ើម៉េះគ្មានបង្អង់
កាយស្គមទ្រមណាស់ខះខំផ្លង់ បំកោងអស់អង្គដំរង់ឋាន ។
សែងព្រះអាទិត្យរឹតក្តៅលន់ បន្ទុករឹងធ្ងន់លើសធន់បាន
ខំទប់ឈប់ស្ងៀមត្រៀមប្រុងប្រាណ ឲ្យស្រាន្តកាលណាអូសជាថ្មី ។
អ្នកបរក៏ខឹងប្រឹងវាយវាត់ ប្រឹងធាក់ប្រឹងទាត់ប្រឹងជេរស្តី
“ដើអាកញ្ចាស់ខូចណាស់វ៉ី វាយអាឲ្យល្បើយកថ្វីដៃ” ។
ថាហើយសំពងដូចគេដាប់ ខ្ទាប់ៗ ស័ព្ទសូរសំបើមក្រៃ
សត្វឈឺព្រឹខំឥតសំបៃ ប្រឹងអស់សរសៃធ្លុងកែងដួល ។
ហត់ពេកដេកស្តឹកក្រោកពុំបាន រំខានទឹងថ្កល់ខ្យល់មិនស្រួល
រហាមតាមកម្មចាំទទួល រំពាត់រមួលរមាសស្បែក ។
ឯម្ចាស់ក្តៅណាស់ផ្តាសារះផ្ទៀត វាយហើយវាយទៀតគំពមស្រែក
ហៅសែនរបឹងរឹងដូចដែក បំឡែកប៉ែកអស់គេធម្មតា ។
អស់ចិត្តអស់ចង់បង់កំឡាំង រម៉ោករម៉ាំងចុះឆ្វេរឆ្វា
ស្រាយសេះបេះអានចេញពីស្នា ធាក់ច្រានផ្កាប់ផ្ងារលើប្រថពី ។

រួចជូតញើសថ្ងាសដោយមួម៉ៅ    ទើបចាប់បោះស្មៅឲ្យសេះស៊ី
តែសត្វវិបត្តិកុនសៀធី    មើលទិសមើលទីពុំយល់ឡើយ ៗ
ក្អែកស្រែបែរមើលទៅរទេះ    ភក្ដីអ្វីម្ល៉េះឱសេះអើយ
ដាបម្ជុំប្រឹងគិតមិនអស់ហើយ    ចង់ស្បើយក្រោកអូសទៅឲ្យបាន ៗ
នៅតែមានចិត្តអាណិតមនុស្ស    តតគិតប្រទុស្តតតបក្កាន
ទ័លតែក្សីណក្ស័យប្រល័យប្រាណ    ស្លូតត្រង់ស្មោះស្មានរាប់អានម្ចាស់ ៗ
ហេតុគ្នាជាសត្វពុំចេះស្ដី    ពុំមានប្រណីបែរក្រឡាស់
វាយដំប្រំចាក់អាក្រក់ណាស់    អាងខ្លួនជាម្ចាស់ត្រួតលើវា ៗ
បានផលប្រយោជន៍ខ្លួនទេតើ    គ្រាន់បើបានល្អព្រោះតែគ្នា
ខំប្រឹងអូសទឹមរាល់វេលា    មិនចេះរួញរារើគំនិត ៗ
អនិច្ចាសេះសត្វបាត់វិញ្ញាណ    ពុំមាននរណាមេត្តាគិត
មានតែសត្វក្អែកស្រែកជុំជិត    សង្វេគពេកពិតជីវិតសត្វ! ៗ

សាំង · សុវេទ្យ

---

បើឆ្កួតឲ្យចំជាឆ្កួតសុទ្ធ    បើជាជាផុតនេះស្រួលងាយ
ស្ទើរឆ្កួតស្ទើរជាលេលាលាយ    មិនងាយទេនេះសែនពិបាក ៗ

ញ. ស.

## ការសង្កេតខ្លះៗ អំពីរបៀបតែងសេចក្ដី

**១ – មេគំនិត –** ទីងតែងសេចក្ដីនិពន្ធជារឿងអ្វីៗ ទៅបាន លុះត្រាតែយើងដឹងច្បាស់ថា តើយើងត្រូវការបង់និយាយអ្វី តាមមេគំនិតបែបណា ។ ឯមេគំនិតនេះកម្រនឹងផុះផុលឡើងឯងស្រាប់ៗ គ្រប់តែពេលដែលត្រូវការនោះណាស់ គោងតែយើងចំសន្សំនូវមេគំនិតនោះទុក បីដូចជាគរទូវពូជសំរាប់យកទៅសាបព្រោះបណ្ដុះក្នុងឱកាសណា ក៏បាន ដោយប្រើការសង្កេតជុំវិញខ្លួន ក្នុងពេលចេញដើរពីផ្ទះទៅ ពេលកំពុងធ្វើការ ពេលដើរកំសាន្ត ពេលមានប្រជុំជាដើម ឬដោយការអានសៀវភៅក្បួនខ្នាតផ្សេងៗ ហើយបើបានប្រទះការណ៍ណាដែលចំឡែកជាទីចាប់ចិត្ត គោងកត់ទុកក្នុងកំណត់មួយដោយឡែកចំនួន ១០ ឬ ២០ បន្ទាត់ដោយសង្ខេប ហាត់កត់ត្រាបែបនេះរៀងរាល់យប់កុំបីខាន កិច្ចការនេះនឹងនាំឲ្យយើងចេះមើល ចេះស្ដាប់ ចេះអាន ចេះរាយដំឡៃមេគំនិត ។

**២ – សម្ភារៈអ្នកនិពន្ធ –** សម្ភារៈអ្នកនិពន្ធ គឺការអាន ការសង្កេត ការសិក្សា ដែលមានកំណត់ជាផល ។ កំណត់នេះជាទ្រព្យដ៏ប្រសើរនៃអ្នកនិពន្ធទាំងឡាយ តែកំណត់នេះមិនត្រូវចេះតែស្រង់គ្រប់រឿងដែលបានជួបប្រទះនោះទេ គួរកត់តែហេតុការណ៍ណាដែលប្លែក ដែល

ទាក់ទងក្នុងបច្ចុប្បន្នការណ៍ ដែលនឹងចំរើនទៅខាងមុខ ដែលទាក់ទងដល់រឿងដែលយើងត្រូវការសិក្សា គឺជាអ្វីដែលយើងអាចទុកជាឯកសារសំរាប់កិច្ចការរបស់យើងបាន ។ ឯកំណត់អស់នោះគោងចុះតាមពួកតាមរឿង ទុកក្នុងកន្ទែងផ្សេងគ្នា ដូចជា ផ្នែកសាសនា - អក្សរសាស្ត្រ-កាព្យ · ចិត្តវិទ្យា - បុគ្គលិកលក្ខណៈជាដើម ដើម្បីឲ្យងាយដល់ការរក ។

៣ — **ការពិនិត្យមើលគំនិត** — គំនិតណាដែលលេចឡើងហើយ, ហើយយើងត្រូវការទឹងសំដែងនូវគំនិតនោះជាលាយលក្ខណ៍អក្សរ យើងគោងពិចារណាឲ្យល្អិតល្អន់ជាមុនសិន ឲ្យដឹងថាតើជាគំនិតថ្មីល្មមនឹងអធិប្បាយកំចាយសេចក្ដីឬទេ? ល្មមជាការប្រមូលឯកសារចំពោះរឿងនោះគ្រប់គ្រាន់ហើយឬនៅ? ការបញ្ជាក់របស់យើងនោះ បានជាសេចក្ដីវិនិច្ឆ័យបរិបូណ៌ឬទេ? ពិតជាដូច្នោះមែនឬដូចម្ដេច? ។ សេចក្ដីពិចារណាយ៉ាងនេះជាដើម ជាករណីយកិច្ចនៃអ្នកនិពន្ធ ដែលត្រូវតែពិនិត្យដោយមធ្យ័តចំពោះខ្លួនឯងក្នុងពេលផ្ដើមកិច្ចការរបស់ខ្លួន ព្រោះកិច្ចការនោះមានផលជាច្រើននាក់ចាំអាន ។ ដូច្នេះយើងត្រូវសរសេរមើលគំនិតនោះជាគោលទុកពិនិត្យ តើសមដូចវត្ថុបំណងរបស់យើងហើយឬនៅ ហើយគោងបង្កើតឧត្តមគតិឬទស្សនៈជាន់ខ្ពស់ ឲ្យប្រាកដច្បាស់ឡើងទៀត ដើម្បីនិពន្ធរឿងផ្សេងៗ ។ វត្ថុដែលអ្នកអានត្រូវការស្វែងរកក្នុងសៀវភៅមើលនោះ គឺអ្វីដែលមើលទៅហើយនាំឲ្យមានសេចក្ដីដឹងវិសេសឡើង

ឲ្យអណ្ដែតអណ្ដូងចិត្ត ឲ្យញាប់ញ័ររំភើប ឲ្យស្ញើចអស្ចារ្យ ឲ្យបានក្រេប នូវរសជាតិដែលខ្លួនប្រាថ្នាជាដើម, រឿងណាដែលជាការធម្មតា ដូចជា “មនុស្សខ្វាក់មើលទិសតំបន់ពុំយល់” ឥតមាននរណាគេចង់ដឹងទៀតទេ ព្រោះគេដឹងរួចទៅហើយ បើយើងអធិប្បាយពីប្រស្នាថា “ហេតុអ្វី បានជាមានមនុស្សខ្វាក់មើលអ្វីពុំយល់? រឿងនោះនឹងជាទីចាប់ចិត្តពុំខាន តែបើប្រស្នានោះមានគេដោះស្រាយរួចមកហើយ យើងតោងតែរកហេតុ ផលឲ្យសមរម្យប្រកបច្បាស់លាស់ជាងដែលគេបាននិយាយមកហើយ នោះទៅទៀត, បើនិយាយដូចតែគេដដែលទេ ដាក់ដងប៉ាកកាចុះទៅ ប្រសើរជាង ។

**៤– ផែនការ** ការនិពន្ធនីមួយៗ នឹងចោលផែនការពុំបានដោយ ជាប់ខាត ព្រោះផែនការនេះជាគ្រឿងផ្សំផ្គុំនូវគ្រោងនៃរឿងរបស់យើង ឲ្យសមរម្យត្រឹមត្រូវបីដូចការស្ថាបនាគ្រឹះស្ថានទាំងឡាយ ។ រឿងណា ដែលពុំទាន់ចុះក្នុងផែនការល្អិតល្អដរាបណា រឿងនោះក៏នៅពុំទាន់រាប់ចូល ក្នុងអក្សរសាស្ត្រដរាបនោះ ។ អ្នកនិពន្ធខ្មែរយើងច្រើនតែមិនស្គាល់ដំឡែ ផែនការ ចង់សរសេរអ្វីស្រាប់តែចាប់សរសេរយកតែម្ដងតាមដែលនឹក ឃើញ ម៉្លោះហើយស្នាដៃដែលចេញមកច្រើនតែរកវគ្គបំណងពុំឃើញ ពុំ ដឹងជាចង់ថាអ្វី ចេះតែទៅមុខរកចប់ពុំឃើញ, ជួនកាលមានភាគខ្លះមិនសម សួននឹងគ្នា ត្រង់ណាវែងៗ ហួសហេតុ ត្រង់ណាខ្លីៗ ខុសបទ បញ្ចេញឲ្យ

ឃើញថាមិនបេះគ្រប់គ្រង់គំនិតរបស់ខ្លួន ៗ កិច្ចការឯណាមួយតែប្រាស ចាកវិន័យនឹងរបៀបរៀបរយហើយ កិច្ចការនោះមិនចំរើនទេ ៗ វិន័យនឹងរបៀបរៀបរយនេះមាននៅក្នុងការរៀបចំផែនការនោះឯង ៗ ដូច្នេះ អ្នកនិពន្ធដែលមានសេចក្ដីគោរពចំពោះខ្លួនឯង គប្បីធ្វើផែនការដោយហ្មត់ចត់ គឺត្រាទុកនូវភាគផ្សេងៗ នៃរឿងដោយសង្ខេបខ្លីៗ រួចកាត់ជាបទគ្រប់បទតទៅទៀត ពិនិត្យមើលតើភាគផ្សេងៗ នោះ ទាក់ទងចុះគន្លងគ្នាឬទេ ឬក៏ដកត្រង់ណា បន្ថែមត្រង់ណាជាដើម ៗ ការឧហាតព្យាយាមធ្វើផែនការនាំឲ្យជួបប្រទះនូវភាពចំកំប៉ាំងនៃសំនួនវោហារ នូវតុល្យភាពនៃភាគនានា ក្នុងរឿងនីមួយៗ ហើយនាំឲ្យកិច្ចការនោះរឹងដំហារ មានសំរស់មានបដិភាគនិមនួន ៗ

**៥ — ការកំណត់បន្ទាត់** - ក្នុងការតាំងផែនការ គេតែងឲ្យដឹងចំនួនបន្ទាត់ដែលយើងត្រូវសរសេរជាមុន ព្រោះបើយើងសរសេររឿងចុះទស្សនាវដ្ដីក្ដី ចុះកាសែតក្ដី ឬបោះជាសៀវភៅផ្សាយក្ដី គេតែងឲ្យដឹងជានឹងកំណត់បន្ទាត់តាមចិត្តចង់ពុំបានទេ គេតែងនិយមទៅតាមសេចក្ដីត្រូវការឬចាំបាច់, បើមិនដូច្នោះទេ មុខជាគេមិនចុះឲ្យ ឬត្រូវគេកាត់ចោលខ្លះដោយខានពុំបាន ៗ កុំនឹកស្មានថាការកំណត់ទុកជាមុនក្នុងផែនការឲ្យគ្រប់ភាគនៃរឿងនោះ នាំឲ្យលំបាកធ្វើពុំកើតឬនាំឲ្យខូចផ្ទៃរឿងរបស់ខ្លួនឡើយ, មិនមែនដូច្នោះទេ មានតែនាំឲ្យរឿងនោះៗ មានដំឡៃទៅវិញ

ព្រោះមិនលាយឡំដោយការណ៍ពេយពយឥតប្រយោជន៍ ។ ការវៃល បន្ទាត់នោះគោងប្រើវិធីដូច្នេះ គឺត្រូវរាប់មើលតើក្នុងទំព័រពុម្ពនីមួយៗ នៃសៀវភៅដែលយើងត្រូវការចុះបុ្កបោះនោះ មានបន្ទាត់ប៉ុន្មានហើយកត់ចំនួនទុក, រួចរាប់ចំនួនអក្សរក្នុង ៤ បន្ទាត់ពេញនៃអក្សរពុម្ពនោះយកបន្ទាត់ត្រង់ណាក៏បាន ឲ្យតែជាបន្ទាត់ពេញគឺគ្មានខ័ណ្ឌដកឃ្លា ហើយយកទៅចែកនឹង ៤ រកចំនួនមធ្យម បានចំនួនមធ្យមហើយត្រូវយកចំនួនបន្ទាត់ដែលត្រូវសរសេរមកគុណ នឹងឃើញចំនួនអក្សរនៃរឿងដែលត្រូវនិពន្ធ នេះសំរាប់អក្សរពុម្ព; សំរាប់អក្សរយើងវិញ យើងត្រូវគិតតាមវិធីដូចគ្នា យើងក៏អាចដឹងបានថាតើត្រូវសរសេរប៉ុន្មានបន្ទាត់នៃអក្សររបស់យើងជាទីបំផុត ។

សុភមិត្រ

---

គេលើកកុំឡើងទៅតាមយស ឡើងខ្ពស់មើលទាបរក្សាមិត្ត
ដើរមុខទុកក្រោយកុំឲ្យជិត លោកប្រែគោងប្រព្រឹត្តចិត្តកុំប្រែ ៗ
កាន់ប្រាជ្ញកុំប្រែបសម្របតាម ហួសហើយកុំហាមឲ្យតាមកែ
បទខ្ញុំគោងរៀបរៀងសបែរ រៀនស្នេហ៍គោងស្និទ្ធចិត្តឲ្យស្ងួន ៗ

សុភាសិតបុរាណ

## បញ្ចតន្ត្រៈ

(តមក)

បិង្គលកៈសួររឿងនោះថា “ ចុះរឿងនោះតើដូចម្តេច ? ។ ចចក ទមនកៈឆ្លើយដូចតទៅនេះថា:

គាថាទី ៣

# រឿងចចកនឹងស្គរ

មានចចកមួយ ស្រេកឃ្លានខ្លាំង ដើរស្វះស្វែងរកចំណីអាហារ ទៅខាងនេះខាងនោះ បានឃើញស្នាមសមរភូមិចាស់មួយដែលកងសេនាទាំងពីរច្បាំងតតាំងគ្នា ។ សេនាទាហានដែលច្បាំងគ្នាហើយដើរបាត់ទៅ ចោលស្គរមួយនៅលើដើមឈើ ។ មែកឈើ កាលណាមានខ្យល់ខ្លាំងបក់ផាត់មក ក៏ហាក់ដូចជាទៅវាយស្គរនោះឮសូរទូងៗ ។ ចចកឮសូរទូងៗ ដូច្នោះភិតភ័យញ័ររន្ធត់ គិតថា: “ ឱអាត្មាអញដល់គ្រោះអន្តរាយហើយតើ ! បើអាត្មាអញនៅឆ្ងាយទៅក៏” ទើបគេចរត់ចេញទៅឲ្យឆ្ងាយ, តែណ្ហើយចុះ អាត្មាអញមិនគួរប្រញាប់លះបង់ចោលព្រៃផាទីឋានដីដូនដីតាទេ, ព្រោះថា:

១០៩ – គង់កាលមានភ័យ ឬក៏មានសេចក្តីកើតកាយមកដល់ អ្នកណាពិចារណា តែមិនធ្វើកិច្ចការអ្វីៗ ដោយប្រញាប់ប្រញាល់តាមគំនិតទេ អ្នកនោះ មិនក្តៅក្រហាយស្តាយក្រោយឡើយ ។ បើដូច្នោះ

គួរអាត្មាអញចូលទៅមើលឲ្យដឹងច្បាស់នូវសំឡេងនេះសិន" ។ បបកគិតដូច្នោះហើយ សំដែងសេចក្ដីក្លាហានយ៉ាងម៉ឺងម៉ាត់ គិតប្រុងស្មៀតបណ្ដើរដើរចូលទៅសន្សឹមៗបណ្ដើរ លុះចូលទៅជិតហើយ ឃើញស្គរមួយទើរនៅលើមែកឈើ ពិនិត្យឃើញថា កាលណាមានខ្យល់បក់មកមែកឈើដែលយោលទៅមកទៅប៉ះនឹងស្គរ ហាក់ដូចជាគេវាយឮស្នូរខ្ទូងៗ កាលណាឥតខ្យល់ ក៏បាត់ឮស្នូរទៅ ។ បបកស្គាល់ច្បាស់ថាជាស្គរ ហើយដើរចូលទៅជិត យកដៃវាយលេងដោយក្ដីចំណង់យ៉ាងរីករាយក្រៃលែងគិតថា 'ឱស្គរនេះបានភោជនាហារច្រើនណាស់ អាត្មាអញមិនដែលបានអាហារច្រើនម៉្លេះទេយូរយារណាស់ហើយ, ខាងក្នុងស្គរប្រហែលជាពេញដោយសាច់ ខ្លាញ់ទឹងឈាមច្រើនក្រៃលែង" ។ លំដាប់នោះ, បបកក៏ខំប្រឹងកកេរចោះស្បែកពាសស្គរដែលរឹងក្រៀមក្រោះ ទាល់តែបាក់ធ្មេញទើបទំលុះបានមួយចំណែក ហើយត្បូលចូលទៅក្នុងស្គរនោះដោយចិត្តរីករាយក្រៃលែង ។ កាលចូលទៅក្នុងស្គរ បបកមិនឃើញមានអ្វី មានតែស្បែកនឹងឈើក៏អាក់អន់ចិត្ត ពោលជាស្លោកដូចជាខ្ញុំបានដឹងហើយ (លេខ ១០៨) ។

ព្រោះហេតុដូចខ្ញុំបាទបានពោលមកហើយ បុគ្គលមិនគប្បីភ័យខ្លាចរហូតដល់ទៅបាត់ស្មារតីទេ សព្វបើគ្រាន់តែឮសំឡេង ។ បង្កុលកៈឆ្លើយតទៅទៀតថា "នែទមនកៈដ៏ចំរើន! ឯងមើល! បរិពារយើងទាំងអស់គិត

ភ័យញ័ររន្ធត់ប្រឹងតែខ្ញុំរត់ចោលព្រៃនេះទេ បើដូច្នេះឯងឲ្យយើងធ្វើចិត្តក្លាហានម៉ឺងម៉ាត់ដូចម្ដេចកើត?" ។ បចកឆ្លើយថា "បពិត្រលោកម្ចាស់ដំណើរនេះ មិនមែនជាកំហុសសេវកាមាត្យទាំងឡាយនោះទេ, សេវកា-មាត្យទាំងឡាយ អាចនឹងធ្វើឲ្យបានរឹងប៉ឹងម៉ឺងម៉ាត់ដូចលោកជាម្ចាស់ដែរ, ព្រោះថា:

១១០ – សេះ សស្ត្រ សាស្ត្រ ពិណ ពាក្យសំដី បុរស និងស្ត្រី ដែលប្រើការបានល្អ និងមិនបានការល្អ ស្រេចហើយតែបុរសវិសេសចេះប្រើប្រាស់ទេ ។

ដូច្នេះ សូមលោកម្ចាស់តាំងព្រះទ័យជាបុរសក្លៀវក្លាហាន ហើយគ្រប់គ្រងទីឋាននេះ ទំពាំខ្ញុំបាទទៅមើលឲ្យស្គាល់ដំណើររូបនៃសំឡេងនោះឲ្យដឹងពិតប្រាកដហើយត្រឡប់មកវិញសិន ក្នុងកាលណា យើងនឹងគិតគូរគ្នាតទៅទៀតក្នុងកាលនោះ" ។ បិង្គលកៈលាន់មាត់សួរថា "ឃើ! អ៊ីឯងហ៊ានចូលទៅមើលដល់ទីនោះ?" ។ បចកទមនកៈឆ្លើយថា "បពិត្រលោកម្ចាស់! បើលោកម្ចាស់ត្រាស់បង្គាប់, សេវកាមាត្យល្អត្រូវតែធ្វើតាម ទោះជាកិច្ច ឬមិនមែនកិច្ច ព្រោះថា:

-១១១ – តាមសេចក្ដីបង្គាប់នៃម្ចាស់ សេវកាមាត្យល្អ មិនត្រូវខ្លាចអ្វីមួយសោះ សូម្បីចូលទៅក្នុងរូងនៃផែនដី នឹងទៅកាន់ហាមសមុទ្រដែលគេទៅបានដោយកម្រ ។

១១២ — សេវកាមាត្យណា ដែលទទួលសេចក្តីបង្គាប់ពីម្ចាស់ផែនដីហើយ គិតពីស្រួលនឹងមិនស្រួល លំបាកនឹងមិនលំបាក សេវកាមាត្យនោះ ព្រះរាជាដែលប្រាជ្ញអំណាចមិនត្រូវរក្សាទុកឡើយ" ។

បិង្គលកៈស្តាប់ហើយឆ្លើយថា "ហៃអ្នកដ៏ចំរើន! បើដូច្នោះ ឯងចូរទៅចុះ សូមឲ្យឯងបានសេចក្តីសុខ មានសិរីសួស្តីជ័យជំនះតាមផ្លូវ" ។ ឯទមនកៈប្រណម្យក្រាបបង្គំលាចេញទៅ ដើរសំដៅទៅកាន់ទីឋានដែលឮសំឡេងរោទ៍នៃសញ្ជីវកនោះ ។ កាលក្រោយដែលទមនកៈចេញផុតទៅហើយ បិង្គលកៈភ័យព្រួលច្របល់ខ្វល់ក្នុងចិត្តឥតឧបមា គិតផ្អុកៗក្នុងពោះថា "ឱ! អាត្មាអញធ្វើនេះមិនល្អទេ ស្តាយណាស់ មិនគួរទៅស្និទ្ធស្នាលទុកចិត្តទុកថ្លើម អភិប្រាយអាថ៌កំបាំងខ្លួនប្រាប់ចចកនេះឲ្យដឹងសោះ, ទមនកៈនេះ ប្រហែលជាមនុស្សក្បាលពីរចូលមកសំណាក់អាត្មាអញដោយគំនិតអាក្រក់ ព្រោះខូចខាតដំណែងខ្លួនទេដឹង? ព្រោះថា:

១១៣ — ព្រះរាជាទ្រង់ប្រោសប្រាណសេវកាមាត្យណា ហើយទ្រង់លែងប្រោសប្រាណទៅវិញ សេវកាមាត្យនោះ បើទុកជាមានត្រកូលខ្ពង់ខ្ពស់ ក៏តែងតែរកឧបាយធ្វើគត់ព្រះរាជានោះវិញគ្រប់កាលទាំងពួង ។

បើដូច្នោះ គួរអាត្មាអញទៅពួនក្នុងទីដទៃ រក្សាខ្លួនហើយឈប់ចាំមើលឲ្យដឹងថា វាគិតធ្វើអ្វីខ្លះសិន ទមនកៈនេះ ទំនងជាទៅនាំយកសត្វធំនោះមក ហើយព្រួតគ្នាសម្លាប់អាត្មាអញក៏សឹងថាបាន, ព្រោះថា:

១១៨— នរជនមានកម្លាំងខ្សោយ តែជាអ្នកមិនជឿទុកចិត្តគេ សូម្បីអ្នកមានកម្លាំងខ្លាំងក៏មិនអាចសម្លាប់បាន, អ្នកមានកម្លាំងខ្លាំង តែជាអ្នកជឿទុកចិត្តគេ សូម្បីអ្នកមានកម្លាំងខ្សោយក៏អាចសម្លាប់បាន ។

១១៩ (១) អ្នកប្រាជ្ញដែលមានមតិធំជ្រាលជ្រៅ មិនដែលប្រគល់ការជឿទុកចិត្តចំពោះសត្រូវទេ ព្រោះតែការជឿទុកចិត្តហើយ បានជាព្រះរាជបុត្រព្រះបាទទិតិ (២) នៅក្នុងគភ៌ ត្រូវព្រះឥន្ទ្រទំលាយបង់ចោលបាន ” ។

បិង្គលកៈកាលគិតគូរល្អិតល្អន់យ៉ាងនេះហើយ ក៏គេចពីទីកន្លែងដើម ទៅរកទីដទៃទៀតតែម្នាក់ឯង ហើយឃ្លាំចាំមើលចចកត្រឡប់មកវិញ ។

---

១ បញ្ចតន្ត្រៈ សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់ស៊ឺរ មានគាថាលើសខ្លះទៀត: ក. អ្នកប្រាជ្ញដែលប្រាថ្នាសេចក្ដីចំរើន អាយុវែង និងសេចក្ដីសុខ មិនត្រូវជឿទុកចិត្តគេ សូម្បីព្រះព្រហស្បតី ។ ខ. បុគ្គលមិនគប្បីជឿទុកចិត្តសត្រូវ សូម្បីសត្រូវដែលផ្សះផ្សាជាមួយគ្នាហើយដោយសំបថ ព្រោះតែជឿសំបថ ព្រះឥន្ទ្រនោះគេសម្លាប់ព្រះវ្ឫត្រ (គឺអសុរ) ដែលដណ្ដើមរាជសម្បត្តិ ។

២ ព្រះបាទទិតិបានបន់សូមកូនប្រុសមួយពីព្រះកស្សបៈ ឲ្យខ្លាំងពូកែជាងព្រះឥន្ទ្រ ព្រះឥន្ទ្រប្រណែន ក្លែងខ្លួនចូលទៅក្នុងគភ៌ព្រះទិតិ យកព្រះខ័នពេជ្រកាត់កូនក្នុងគភ៌ជា ៧ កំណាត់ ក្នុងមួយកំណាត់ៗ ព្រះឥន្ទ្រចិញ្ច្រាំកាត់ជា ៧ ចំណែកទៀត ។ ចំណែកគភ៌ទាំងអស់នេះ កើតទៅជាព្រះវាយុ មានរូប ៤៩ យ៉ាង បានជាមានរឿងព្រេងដំណាលថា ព្រះឥន្ទ្រជាម្ចាស់ឋានសួគ៌, ឯអាកាស ឲ្យព្រះវាយុជាម្ចាស់ ចែកជា ៤៩ ទិស ។

ឯទមនកៈ ដើរចូលទៅជិតគោសញ្ជីវកៈ ស្គាល់បានថាជាគោដូច្នេះហើយ រីករាយសប្បាយចិត្តណាស់គិតថា "ឱ! មានសុភមង្គលធ្លាក់មកដល់ហើយតើ! អាត្មាអញ នឹងយកការបងស្ពានមេត្រីនឹងសង្គ្រាមនៃសត្វទាំងពីរនេះជាទ្វារ ហើយធ្វើបិង្គលកៈឲ្យទៅក្នុងអំណាចអាត្មាអញទាល់តែបាន, ព្រោះថាៈ

១១៦ – ព្រះនឫបតី ទ្រង់មិនដែលអនុវត្តន៍ទៅតាមពាក្យមន្ត្រីទេ សូម្បីមន្ត្រីនោះជាអភិជន ឬជាបុគ្គលមានមេត្រី លុះត្រាតែទ្រង់មានសេចក្តីអន្តរាយ ឬមានសេចក្តីទុក្ខសោក ទើបទ្រង់អនុវត្តន៍តាម ។

១១៧ – គ្រប់កាលទាំងពួង ព្រះរាជាដែលមានសេចក្តីទុក្ខព្រួយធ្លាក់មកដល់ រមែងទៅជាគ្រឿងលេងនៃមន្ត្រីទាំងឡាយ ព្រោះហេតុនោះឯង បានជាមន្ត្រីតែងត្រូវការព្រះនឫបតីដែលទ្រង់មានទុក្ខ ។

១១៨ – នរជន មិនមានរោគាព្យាធិ មិនត្រូវការរកគ្រូពេទ្យយ៉ាងណា ឯព្រះរាជាដែលមិនមានសេចក្តីទុក្ខ ទ្រង់មិនត្រូវការរកសេវកាមាត្យយ៉ាងនោះដែរ" ។

ទមនកៈ លុះគិតរកឧបាយឃើញយ៉ាងនេះហើយ ក៏ធ្វើដំណើរឆ្ពោះទៅកាន់សំណាក់បិង្គលកៈ ។ បិង្គលកៈ កាលក្រឡេកមើលទៅឃើញទមនកៈដើរត្រឡប់វិលមកវិញ ទៅអង្គុយនៅកន្លែងដើម ធ្វើអាការមុខមាត់ដូចប្រក្រតី លាក់មិនឲ្យបបកដឹងដើមដានឡើយ ។ ទមនកៈ

ដើរចូលទៅកាន់សំណាក់បិង្គលកៈ លើកទសករប្រណម្យហើយចូលទៅអង្គុយជិត ។ បិង្គលកៈធ្វើហាក់ជាត្រេកអរសួរទៅភ្លាមថា: "ម៉េចទៅ! ឯងទៅនេះ បានឃើញអាសត្វបៃងនោះទេ ?" ។ ទមនកៈឆ្លើយតបថា: "សូមលោកម្ចាស់មេត្តាប្រោស អាសត្វនោះ ខ្ញុំបាទឃើញវាហើយ" ។ បិង្គលកៈសួរបញ្ជាក់ថា: "ឯងឃើញពិតប្រាកដមែនឬអី ?" ។ ទមនកៈឆ្លើយតបម្តងទៀតថា: "ចំពោះព្រះភ័ក្ត្រព្រះស្វាមិបាទ នរណាឡើយហ៊ាននិយាយពាក្យមិនពិត, ព្រោះថា:

១១៩ – នរជនណា ហ៊ាននិយាយពាក្យកុហកសូម្បីបន្តិចបន្តួចចំពោះព្រះភក្ត្រម្ចាស់ផែនដីឬចំពោះទេវតា នរជននោះ ទោះបីស័ក្តិធំប៉ុនណា ក៏នឹងវិនាសខ្ទេចខ្ទីក្នុងមួយរំពេច ។

១២០ – អ្នកប្រាជ្ញមនុពោលទុកថា "ព្រះរាជាទាំងឡាយជាទេវតានៃទេវតាទាំងពួង" ព្រោះហេតុនោះ នរជនត្រូវគោរពព្រះរាជាអង្គនោះៗ ហើយមិនត្រូវពោលពាក្យកុហកឡេះឡោះឡើយ ។

១២១ – ម្ចាស់ផែនដី ជាទេវតានៃទេវតាទាំងពួង ទ្រង់ប្រទានរង្វាន់ ដាក់ទោសទណ្ឌកម្មមួយរំពេច ឯទេវតាឲ្យល្អអាក្រក់តែក្នុងលោកនេះទេ នេះជាសេចក្តីវិសេសប្លែកគ្នា" ។

បិង្គលកៈសួរបញ្ជាក់ហើយបញ្ជាក់ទៀតថា: "ឯងឃើញវាពិតប្រាកដមែនឬអ្វី? និយាយឲ្យពិតមក អ្នកធំមិនក្រេវក្រោធចំពោះអ្នកតូចខ្សត់ខ្សោយទេ ហើយឯងក៏គេមិនត្រូវសម្លាប់ដែរ, ព្រោះថា:

១២២ – ខ្យល់មិនបោកបក់រំលើងស្មៅដែលទុទន់ទោរទៅគ្រប់ទិសដំបន់ទេ នេះជាសភាពនៃបុគ្គលធំតូចក្នុងលោកនេះ អ្នកធំធ្វើសង្គ្រាមចំពោះតែអ្នកធំ ដូចខ្យល់បក់រំលំតែឈើណាដែលធំៗ ។

១២៣ – ដំរីសូម្បីចុះប្រេងខ្លាំងក្រៃលែង ហើយមានកមរជាតិដែលស្រវឹងហើរក្លៀលឆ្កាត់រលវង់ព្រានព្រាតពេចកំផ្ញៀង ទិចបាតដៃបាតជើង ព្រោះចិត្តជាប់ក្នុងប្រេងដំរី ក៏មិនក្រេវក្រោធឡើយ ឯបុគ្គលមានកម្លាំងក្លៀវក្លាហាន តែងក្រេវក្រោធតបំពោះតែបុគ្គលដែលមានកម្លាំងធំប៉ុនគ្នា" ។

ទមនកៈឆ្លើយបណ្ដាយថា: " យ៉ាងនេះមែនហើយ សត្វនោះធំណាស់ ឯរូបយើងតូច, ក្នុងរឿងនេះ បើលោកម្ចាស់សព្វព្រះទ័យបង់បាន ខ្ញុំបាទនឹងទៅនាំយកវាមកថ្វាយឲ្យវាធ្វើជាសេវកាមាត្យលោកម្ចាស់" ។ បិង្គលកៈបើកភ្នែកធំៗ និយាយបែបភ្ញាក់ព្រើតថា: "ឃើ ! អើឯងមានកម្លាំងដល់ម្ល៉េះ? ឯងនឹងអាចធ្វើយ៉ាងនេះដូចម្ដេចបាន?" ។ ទមនកៈនិយាយបែបព្រងើយថា: "អ្វីមួយដែលគេមិនអាចធ្វើបានដោយប្រាជ្ញា, ព្រោះថា:–

១២៤ – នឹងថាដោយគ្រឿងអាវុធក៏មិនមែន នឹងថាដោយហត្ថីក៏មិនមែន នឹងថាដោយសេះក៏មិនមែន ឬនឹងថាដោយពលថ្មើរជើងក៏ឥតអង្គីមានដែរ កិច្ចការទាំងឡាយ ដែលនឹងសម្រេចទៅបានល្អបំផុតនោះ គឺកិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា" ។

បិង្គលកៈ និយាយបញ្ឆោតថាៈ " បើបានសម្រេចដូច្នោះមែន យើងនឹងតាំងឯងលើកដំកើងឲ្យឡើងថ្នាក់ធ្វើជារដ្ឋមន្ត្រីចាប់តាំងពីពេលនេះតទៅ ធ្វើការអ្វី យើងមិនលះបង់ឯងចោលទេ ទោះជាអំពើគួរឲ្យជ្រះថ្លាក្តី អំពើសង្កត់សង្កិនគេក្តី ឬអំពើអ្វីដទៃទៀតក្តី នេះជាពាក្យប្តេជ្ញារបស់យើង" ។ កាលនោះ ទមនកៈត្រឡប់ទៅនាំយកគោសញ្ជីវកៈមកដោយប្រញាប់ប្រញាល់ទៅដល់ហើយនិយាយកំហែងថាៈ "នែអាគោចង្រៃ! បិង្គលកៈម្ចាស់យើងបង្គាប់ឲ្យហៅឯងទៅឆាប់ៗ អាឯង! ហេតុអ្វីក៏ឥតកោតក្រែងរអែង អាអ្នកណាសោះ ស្រែកកេទញយៗចុងគេឯងឥតប្រយោជន៍ដូច្នេះ?" ។ គោសញ្ជីវកៈ បានស្តាប់ពាក្យទមនកៈ ហើយភ័យស្លន់ស្លោសួរទៅថា "ឱ! សម្លាញ់ដ៏ចំរើនអើយ! បិង្គលកៈជាអ្វី?" ។ ទមនកៈស្រែកសន្ធាប់ថាៈ "យី! អាឯងមិនស្គាល់លោកម្ចាស់យើងទេឬអ្វី? មិនអីទេ បន្តិចទៀត ឯងដឹងខ្លួនហើយ, ម្ចាស់យើងឈ្មោះបិង្គលកៈជាសត្វសីហៈធំ មានអំណាចសម្បើមអស្ចារ្យ ចិតនៅក្រោមគល់ដើមជ្រៃចោមរោមដោយម្រឹគជាបរិវារ" ។ គោសញ្ជីវកបានស្តាប់ពាក្យទមនកៈប្រាប់សព្វគ្រប់ តក់ស្លុតបាត់ស្មារតីដូចជាស្លាប់ ព្រួយចិត្តស្ទើរប្រេះទ្រូងនិយាយញ័រមាត់ញ័រកថាៈ "ឱសម្លាញ់ដ៏ចំរើនអើយ! ខ្ញុំមើលទៅសម្លាញ់ឃើញមានចិត្តស្មោះត្រង់ ប្រសប់ប៉ុនប៉ាវសំដីថ្វីមាត់ក្រាន់បើ

# សេចក្តីថ្លែងការណ៍គណៈកម្មាធិការ

សមាគមមិត្តសាលាបាលី បានតាំងគណៈកម្មការសន្និសីទខ្មែរ ពីថ្ងៃ ១២ ខែកុម្ភៈ ១៩៥០ ដោយមានលោក សម-ញាណ ជាប្រធាន, លោក អ៊ុច-រស់, ចាប-ពិន, អ៊ូ-គង់, ម៉ុញ-នារ៉ី, ទិន-ហួត, ម៉ម-យ៉ែម, ម៉ៃ-ប៉ាន់ ជាសមាជិក ។ សន្និសីទនេះ កំណត់ធ្វើនៅសាលាបាលីជាន់ខ្ពស់-ភ្នំពេញ ក្នុងមួយខែម្តងរៀងរាល់ខែ ។

---

គណៈកម្មការអក្សរសាស្ត្រនៃសមាគមមិត្តសាលាបាលីត្រូវការប្រមូលជីវប្រវត្តិរបស់អ្នកប្រាជ្ញខ្មែរទាំងឡាយ (ប្រវត្តិរបស់អ្នកប្រាជ្ញខ្មែរដែលរស់នៅសព្វថ្ងៃ) ដើម្បីយកទៅរក្សាទុកបំរុងនឹងបោះពុម្ពផ្សាយតទៅអនាគត ។ បើអស់លោក-អ្នកអាចរកនឹងជីវប្រវត្តិនេះបាន សូមផ្ញើទៅឲ្យទីសំណាក់ការនៃសមាគមនេះលេខ ៣៥-អា, វិថីឧកញ៉ា ពេជ្រ-ភ្នំពេញ ។

---

**កែតម្រូវ** ៖– សៀវភៅលេខ ១ ត្រង់វិចារណកថា ទំព័រ ៣ បន្ទាត់ ៨= "រហូតដល់ទៅមិនដឹងថា" កែជា "រហូតដល់ទៅដឹងថា" ។ សៀវភៅលេខ ៧ ត្រង់សេចក្តីថ្លែងការណ៍គណៈកម្មាធិការ ទំព័រ២៧៩ បន្ទាត់ ១= "បានបង្កើតសាលាសមាគម" កែជា "បានបង្កើតសាខាសមាគម" ។

IMPRIMERIE ROYALE